




វត្ថុបំណង
រៀនឲ្យដឹងថា
តើព្រះបន្ទូលរបស់ព្រះគ្រិស្តមានគុណប្រយោជន៍យ៉ាងណា
តើអ្នកត្រូវនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្តដោយរបៀបណា
ដើម្បីឲ្យជីវិតរបស់អ្នកមានការផ្លាស់ប្រែនិងបង្កើតផលផ្លែជាច្រើន
តាមរយៈការនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត។

១.សិស្សរបស់ព្រះគ្រិស្តនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត
1. THE DISCIPLES OF CHRIST ABIDE IN THE WORDS OF CHRIST
យ៉ូហាន ៨:៣១
៣១ ពេលនោះ ព្រះយេស៊ូមានព្រះបន្ទូល
ទៅកាន់ជនជាតិយូដាដែលបានជឿលើព្រះអង្គថា៖
«ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹង ពាក្យរបស់ខ្ញុំ អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។



មានមនុស្សពីរប្រភេទក្នុងចំណោមជនជាតិយូដាដែលជឿលើព្រះយេស៊ូនាសម័យនោះ
គឺអ្នកជាន់ទូកពីរដែលព្យាយាមប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះគ្រិស្តផងនិងក្រឹត្យវិន័យផង
និងអ្នកជាន់ទូកតែមួយដែលនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្តសុទ្ធសាធ។
ព្រះយេស៊ូដាស់តឿនជនជាតិយូដាដែលជឿលើព្រះអង្គនាសម័យនោះ
ឲ្យនៅជាប់នឹងព្រះបន្ទូលរបស់ព្រះអង្គ។ ព្រះអង្គបានអះអាងប្រាប់គេថា៖
១.គេនឹងស្គាល់សេចក្ដីពិត
ហើយសេចក្ដីពិតនឹងរំដោះគេឲ្យមានសេរីភាព( យ៉ូហាន ៨:៣២ )
២.ប្រសិនបើព្រះបុត្រារំដោះគេរាល់គ្នា
គេរាល់គ្នាពិតជាមានសេរីភាពមែន( យ៉ូហាន ៨:៣៦ )
៣.ប្រសិនបើពួកគេជាពូជរបស់លោកប្រាហាំ
ហើយព្រះជាម្ចាស់ពិតជាបិតារបស់ពួកគេមែន នោះពួកគេមុខជាធ្វើដូចលោកអប្រាហាំដែរ
គឺស្រឡាញ់ព្រះយេស៊ូ( យ៉ូហាន ៨:៣៩,៤២ )។

២.គុណប្រយោជន៍នៃការនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត

2. THE PROFIT OF ABIDING IN THE WORDS OF CHRIST

ក.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់ជំនឿដល់យើង

B. THE WORDS OF CHRIST GIVES US FAITH

រ៉ូម ១០:១៧

១៧ ដូច្នេះ ជំនឿ កើតមកពីសេចក្តីដែលយើងបានស្តាប់
រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ត ។

មនុស្សលោកនឹងមានជំនឿលើព្រះគ្រិស្ត( ជំនឿដែលនាំឲ្យទទួលការសង្គ្រោះ )ដោយសារគេឮ(hear) យល់(understand) និងទទួល(accept)ព្រះបន្ទូលរបស់ព្រះគ្រិស្ត។

គ្រិស្តបរិស័ទពង្រឹងជំនឿរបស់គេលើព្រះគ្រិស្ត( ជំនឿដែលនាំឲ្យកើតមានទីសម្គាល់និងការអស្ចារ្យនានា )ដោយសារគេឮ(hear) យល់(understand) និងទទួល(accept) ព្រះបន្ទូលរបស់ព្រះគ្រិស្តជារៀងរាល់ថ្ងៃ។

ខ.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់ជីវិតអស់កល្បជានិច្ចដល់យើង

B. THE WORDS OF CHRIST GIVE US ETERNAL LIFE

យ៉ូហាន ៦:៦៨-៦៩

៦៨ លោកស៊ីម៉ូនពេត្រុសទូលព្រះអង្គថា៖
«បពិត្រព្រះអម្ចាស់ តើឲ្យយើងខ្ញុំទៅរកនរណាវិញ ?
ព្រះបន្ទូលរបស់ព្រះអង្គផ្តល់ ជីវិតអស់កល្បជានិច្ច។
៦៩ យើងខ្ញុំជឿហើយដឹងថាព្រះអង្គពិតជាព្រះដ៏វិសុទ្ធដែលព្រះជាម្ចាស់ចាត់ឲ្យមក»។

មនុស្សលោកនឹងមានជីវិតអស់កល្បជានិច្ច ដោយសារគេឮ(hear) យល់(understand) និងទទួល(accept)ព្រះបន្ទូលរបស់ព្រះគ្រិស្ត។

គ្រិស្តបរិស័ទរក្សាជីវិតអស់កល្បជានិច្ចមិនឲ្យបាត់បង់ទៅវិញ ដោយសារគេឮ(hear) យល់(understand) និងទទួល(accept) ព្រះបន្ទូលរបស់ព្រះគ្រិស្តជារៀងរាល់ថ្ងៃ។

គ.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់ការជូតសម្អាតដល់យើង

C. THE WORDS OF CHRIST WIPE US

យ៉ូហាន ១៥:៣

៣ ពាក្យដែលខ្ញុំបានប្រាប់ធ្វើឲ្យអ្នករាល់គ្នា បរិសុទ្ធ រួចទៅហើយ។



យើងបានស្អាតបរិសុទ្ធផុតសៅហ្មងពេលដែលយើងទទួលការជូតសម្អាតពីព្រះគ្រិស្តតាមរយៈ ការឮ ការយល់ ការទទួល ការចងចាំ និងការប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គរៀងរាល់ថ្ងៃ។

វិសុទ្ធភាពដោយសារព្រះគុណ HOLINESS BY GRACE

● ព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិតម្តងជាសូរេច ( Justification ) ដោយសារការបង្ហូរព្រះលោហិតរបស់ព្រះគ្រិស្ត ( រ៉ូម ៥:៩ )

● ព្រះជាម្ចាស់ប្រោសយើងឲ្យបានវិសុទ្ធម្តងជាសូរេច ( Sanctification ) ដោយសារការថ្វាយព្រះកាយរបស់ព្រះគ្រិស្តជាយញ្ញបូជា ( ហេប្រឺ ១០:១០ )

● ព្រះយេស៊ូលាងជម្រះយើងឲ្យជ្រះរៀងរាល់ថ្ងៃ ( Washing ) ដោយសារព្រះវិញ្ញាណរបស់ព្រះគ្រិស្ត ( យ៉ូហាន ១៣:៥; អេភេសូ ៥:២៦ ) ព្រះវិញ្ញាណរបស់ព្រះគ្រិស្តប្រៀបដូចជាទឹកក្នុងផើង

( The Spirit of Christ is like the water in a basin )

● ព្រះយេស៊ូជូតសម្អាតយើងឲ្យស្អាតរៀងរាល់ថ្ងៃ ( Wiping, Drying ) ដោយសារព្រះបន្ទូលរបស់ព្រះគ្រិស្ត ( យ៉ូហាន ១៣:៥; អេភេសូ ៥:២៦ ) ព្រះបន្ទូលរបស់ព្រះគ្រិស្តប្រៀបដូចជាកន្សែងក្នុងព្រះហស្តព្រះគ្រិស្ត។

( The word of Christ is like the towel in Jesus' hands. )

ឃ.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់អ្វីៗដល់យើងតាមសំណូមពរ

D. THE WORDS OF CHRIST GIVE US WHAT WE REQUEST

យ៉ូហាន ១៥:៧

៧ បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយបើពាក្យខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នា
ចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នាប្រាថ្នាចង់បានចុះ
នោះអ្នករាល់គ្នាមុខតែ បានទទួល ជាមិនខាន។



កាលណាយើងទូលសូមអ្វីមួយ
ស្របតាមព្រះបន្ទូលរបស់ព្រះគ្រិស្ត
នោះមានន័យថាយើងទូលសូមស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។
កាលណាយើងទូលសូមអ្វីមួយ
ស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់
នោះព្រះជាម្ចាស់មុខជាព្រះសណ្តាប់យើងជាក់ជាមិនខាន( ១យ៉ូហាន ៥:១៤ )។
ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់អ្វីៗដល់យើងតាមការទូលសូម។
ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់អ្វីៗដល់យើងតាមសំណូមពរ។

ង.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់អំណរពេញលេញដល់យើង
E. THE WORDS OF CHRIST GIVE US JOY
យ៉ូហាន ១៥:១១
១១ ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់អ្នករាល់គ្នា
ដើម្បីឲ្យអំណររបស់ខ្ញុំស្ថិតនៅក្នុងអ្នករាល់គ្នា
ហើយដើម្បីឲ្យអ្នករាល់គ្នាមាន អំណរពេញលក្ខណៈ។



អំណរពេញលេញរបស់ព្រះគ្រិស្ត THE FULL JOY OF CHRIST
ព្រះគ្រិស្តមានអំណរពេញពោរនៅពេលដែល
យើងឮ(hear)ព្រះបន្ទូលដែលព្រះអង្គបានមានបន្ទូលប្រាប់យើង
យើងយល់(understand)ព្រះបន្ទូលដែលព្រះអង្គបានបើកសម្តែងប្រាប់យើង
យើងទទួល(accept)ព្រះបន្ទូលដែលព្រះអង្គបានប្រទានដល់យើង
យើងចងចាំ(remember)ព្រះបន្ទូលដែលព្រះអង្គបានបង្រៀនយើង
យើងប្រតិបត្តិតាម(observe)ព្រះបន្ទូលដែលព្រះអង្គបានបង្គាប់យើង។

នៅពេលដែលអំណររបស់ព្រះគ្រិស្តស្ថិតនៅក្នុងយើង
នោះយើងនឹងមានអំណរពេញលេញ
ហើយយើងមិនចុះខ្សោយដោយសារបញ្ហាដែលកើតឡើងចំពោះយើងឡើយ
ដ្បិតអំណររបស់ព្រះអម្ចាស់ជាកម្លាំងរបស់យើង( នេហេមា ៨:១០ )។

ច.ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់សេចក្តីសុខសាន្តដល់យើង

F. THE WORDS OF CHRIST GIVE US PEACE

យ៉ូហាន ១៦:៣៣

៣៣ ខ្ញុំនិយាយប្រាប់ដូច្នេះ
ដើម្បីឲ្យអ្នករាល់គ្នាបានប្រកបដោយ សេចក្តីសុខសាន្ត រួមជាមួយខ្ញុំ។
អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរមានសង្ឃឹមឡើង!
ខ្ញុំបានឈ្នះលោកនេះហើយ។

កាលណាយើងឮ យល់ ទទួល ចងចាំ និងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះគ្រិស្ត
នោះយើងនឹងបានប្រកបដោយសេចក្តីសុខសាន្តរួមជាមួយព្រះអង្គដែរ
( សន្តិភាព មេត្រីភាព shalom, peace សុខុមាលភាព wellbeing សុខដុមភាព harmony )
មិនថាយើង គ្រួសារយើង ការងារយើង ឬពន្ធកិច្ចយើងកំពុងប្រឈមមុខនឹងវិបត្តិ( crisis )
បញ្ហា( problem ) ទុក្ខលំបាក( suffering ) ឬការបៀតបៀន( persecution )ប៉ុណ្ណាក៏ដោយ។

ឆ.ព្រះបន្ទូលរបស់ព្រះគ្រិស្តបង្កើតផលផ្លែតាមរយៈយើង

G. THE WORDS OF CHRIST BEAR FRUIT THROUGH US

លូកា ៨:១៥

១៥ រីឯគ្រាប់ពូជធ្លាក់ទៅលើដីមានដីជាតិល្អ
ប្រៀបបីដូចជាអស់អ្នកដែលស្តាប់ព្រះបន្ទូលហើយចងចាំទុកយ៉ាងស្មោះអស់ពីចិត្ត
រហូតដល់បានបង្កើត ផលផ្លែជាច្រើន ដោយចិត្តស៊ូទ្រាំ។

ព្រះបន្ទូលរបស់ព្រះគ្រិស្តបង្កើតផលផ្លែតាមរយៈយើងបានតិចឬច្រើនអាស្រ័យលើ
– ថាតើយើងឮនិងយល់ព្រះបន្ទូលរបស់ព្រះគ្រិស្តបានច្បាស់កម្រិតណា?( ម៉ាថាយ ១៣:២៣ )
– ថាតើយើងឮនិងទទួលព្រះបន្ទូលរបស់ព្រះគ្រិស្តបានច្រើនកម្រិតណា?( ម៉ាកុស ៤:២០ )
– ថាតើយើងឮនិងចងចាំព្រះបន្ទូលរបស់ព្រះគ្រិស្តបានល្អកម្រិតណា?( លូកា ៨:១៥ )
– ថាតើយើងប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះគ្រិស្តបានល្អកម្រិតណា?( ម៉ាថាយ ១៨:២០ )
– ថាតើយើងប្រកាសព្រះបន្ទូលរបស់ព្រះគ្រិស្តបានញឹកញាប់កម្រិតណា?( រ៉ូម ១០:១៤ )

ប្រយោជន៍នៃព្រះបន្ទូលរបស់ព្រះគ្រិស្ត THE PROFIT OF THE WORDS OF CHRIST

ព្រះបន្ទូលរបស់ព្រះគ្រិស្តមានឧត្តមប្រយោជន៍យ៉ាងវិសេសវិសាលប្រាំពីរប្រការដូចតទៅ៖



- ផ្តល់ជំនឿដល់យើង
- ផ្តល់ជីវិតអស់កល្បជានិច្ចដល់យើង
- ផ្តល់ការជូតសម្អាតដល់យើង
- ផ្តល់អ្វីៗដល់យើងតាមសំណូមពរ
- ផ្តល់អំណរពេញលេញដល់យើង
- ផ្តល់សេចក្តីសុខសាន្តដល់យើង
- បង្កើតផលតាមរយៈយើង។

បើអ្នកនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត ជីវិតអ្នកមុខជារីកចម្រើននិងបង្កើតផលមិនខាន។

៣.របៀបនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត

3. HOW TO ABIDE IN THE WORDS OF CHRIST

ក.ស្តាប់ព្រះបន្ទូលរបស់ព្រះគ្រិស្ត

A. HEAR THE WORDS OF CHRIST

រ៉ូម ១០:១៧

១៧ ដូច្នេះ ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់
រីឯសេចក្តីដែលយើង បានស្តាប់ នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រិស្ត។

នៅគ្រាចុងក្រោយនេះព្រះជាម្ចាស់មានបន្ទូលមកកាន់យើងរាល់គ្នា
តាមរយៈព្រះគ្រិស្តជាព្រះបុត្រារបស់ព្រះអង្គ( ហេប្រឺ ១:១-២ )។
ព្រះជាម្ចាស់ជំរុញសិស្សព្រះគ្រិស្តឲ្យស្តាប់តាមព្រះបន្ទូលរបស់ព្រះគ្រិស្ត( ម៉ាថាយ ១៧:៥ )។
ព្យាការីម៉ូសេជំរុញអ៊ីស្រាអែលឲ្យស្តាប់តាមព្រះបន្ទូលរបស់ព្រះគ្រិស្ត( កិច្ចការ ៣:២២-២៣ )។
បើមិនស្តាប់ព្រះបន្ទូលរបស់ព្រះគ្រិស្តទេ យើងគ្មានឱកាសឮព្រះបន្ទូលរបស់ព្រះអង្គឡើយ។



កាលលោកពេត្រុសកំពុងតែមានប្រសាសន៍នៅឡើយ ស្រាប់តែមានពពកដ៏ភ្លឺមកគ្របបាំងគេទាំងអស់គ្នា ហើយមានព្រះសូរសៀងបន្លឺពីក្នុងពពកមកថាៈ«នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ព្រះហឫទ័យនឹងព្រះអង្គណាស់ ចូរស្ដាប់ព្រះអង្គចុះ!»។(ម៉ាថាយ ១៧:៥)

ខ.អានព្រះបន្ទូលរបស់ព្រះគ្រិស្ដ B. READ THE WORDS OF CHRIST

អេភេសូ ៣:៣-៤

៣ ព្រះអង្គបានបង្ហាញគម្រោងការដ៏លាក់កំបាំងឲ្យខ្ញុំស្គាល់
ដូចខ្ញុំទើបនឹងសរសេរយ៉ាងខ្លីខាងលើនេះស្រាប់។
៤ ពេលបងប្អូន អាន សេចក្ដីនោះ
បងប្អូនមុខជាដឹងថាខ្ញុំបានយល់ច្បាស់អំពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រិស្ដ។

លូកា ២៤:២៧

២៧ បន្ទាប់មក ព្រះយេស៊ូបកស្រាយសេចក្ដីដែលមានចែងទុក អំពីព្រះអង្គ
នៅក្នុងគម្ពីរទាំងមូល ចាប់ពីគម្ពីរលោកម៉ូសេរហូតដល់គម្ពីរព្យាការីទាំងអស់។

បើយើងមិនអានព្រះបន្ទូលរបស់ព្រះគ្រិស្ដនិងព្រះបន្ទូលដែលចែងទុកអំពីព្រះគ្រិស្ដទេ យើងគ្មានឱកាសបានយល់ច្បាស់អំពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រិស្ដឡើយ។

គ.យល់ព្រះបន្ទូលរបស់ព្រះគ្រិស្ត C. UNDERSTAND THE WORDS OF CHRIST
ម៉ាថាយ ១៣:១៩,២៣
១៩ រីអ្នកដែលបានឮព្រះបន្ទូលអំពីព្រះរាជ្យតែ មិនយល់
ប្រៀបបាននឹងអ្នកដែលទទួលគ្រាប់ពូជនៅតាមផ្លូវ
ដ្បិតមារកំណាចមកឆក់យកព្រះបន្ទូលដែលបានធ្លាក់ក្នុងចិត្តគេនោះទៅ។
២៣ រីឯអ្នកដែលទទួលគ្រាប់ពូជក្នុងដីមានជីជាតិល្អ
គឺអស់អ្នកដែលបានឮព្រះបន្ទូលហើយ យល់ គេបង្កបង្កើតផល
ខ្លះបានមួយជាមួយរយ ខ្លះបានមួយជាហុកសិប និងខ្លះទៀតបានមួយជាសាមសិប។

នៅពេលដែលអ្នកថ្លែងឬអានព្រះបន្ទូលរបស់ព្រះគ្រិស្ត សូមថ្លែងឬអានឲ្យស្រួលស្តាប់
( មិនតតាក់តតុប not stuttering មិនសោះកក្រោះ not dry មិនយឺតពេក not too slow
មិនលឿនពេក not too fast មិនខ្សោយពេក not too weak មិនឮពេក not too loud )
ដើម្បីឲ្យអ្នកស្តាប់ជក់ចិត្តចង់ស្តាប់និងមានឱកាសអាចយល់ព្រះបន្ទូលរបស់ព្រះគ្រិស្តបាន។

របៀបយល់ព្រះបន្ទូលរបស់ព្រះគ្រិស្ត
HOW TO UNDERSTAND THE WORDS OF CHRIST
យើងអាចយល់ព្រះបន្ទូលរបស់ព្រះគ្រិស្ត
១.ដោយបែកឲ្យដាច់ថាតើព្រះគ្រិស្តកំពុងមានបន្ទូលអំពីសម្ពន្ធមេត្រីមួយណា ?
សម្ពន្ធមេត្រីចាស់ដែលពឹងលើក្រឹត្យវិន័យឬសម្ពន្ធមេត្រីថ្មីដែលពឹងលើព្រះវិញ្ញាណ ?
២.ដោយទទួលយកការបើកសម្តែងរបស់ព្រះវិញ្ញាណ
អំពីគម្រោងការអាថ៌កំបាំងរបស់ព្រះជាម្ចាស់( ១កូរិនថូស ២:១០ )
៣.ដោយទទួលយកការបង្រៀនរបស់ព្រះវិញ្ញាណ
ដែលជួយយើងឲ្យស្គាល់និងនៅជាប់នឹងព្រះគ្រិស្ត( ១យ៉ូហាន ២:២០,២៧ )
៤.ដោយបែរចិត្តគំនិតរបស់យើងទៅរកព្រះគ្រិស្តក្នុងបទគម្ពីរនោះ
គឺសញ្ជឹងគិតអំពីព្រះគ្រិស្តនិងកិច្ចការដែលទ្រង់ធ្វើឲ្យសម្រេចហើយ( ២កូរិនថូស ៣:១៦ )
៥.ដោយមើលឃើញសិរីរុងរឿងរបស់ព្រះគ្រិស្ត
ដែលពេញដោយព្រះគុណនិងសេចក្តីពិត( យ៉ូហាន ១:១៤ )។

## របៀបសញ្ជឹងគិតព្រះបន្ទូលព្រះគ្រិស្ត
## HOW TO MEDITATE ON THE WORDS OF CHRIST
## សំណួរប្រាំដែលនាំទៅរកជីវិតពេញបរិបូណ៌



- តើព្រះអម្ចាស់(ព្រះយេស៊ូ)ត្រូវជាអ្វីនឹងអ្នកក្នុងបទគម្ពីរនេះ?
- តើអ្នកត្រូវជាអ្វីនឹងព្រះអម្ចាស់(ព្រះយេស៊ូ)ក្នុងបទគម្ពីរនេះ?
- តើព្រះអម្ចាស់(ព្រះយេស៊ូ)បានធ្វើអ្វីសម្រាប់(ចំពោះ)អ្នក?
- តើអ្នកឆ្លើយតបយ៉ាងណាចំពោះកិច្ចការរបស់ព្រះអម្ចាស់?
- តើការឆ្លើយតបរបស់អ្នកហុចលទ្ធផលយ៉ាងណា?

Five Questions That Lead To Abundant Life, Barnabas Mam, 2008



មនុស្សខ្លះមិនបានបែរចិត្តគំនិតរកព្រះគ្រិស្តក្នុងបទគម្ពីរដែលគេអានឡើយ
«អ្នករាល់គ្នាខំពិនិត្យពិច័យមើលគម្ពីរព្រោះនឹកស្មានថានឹងបាន
ជីវិតអស់កល្បជានិច្ចដោយសារគម្ពីរទាំងនេះ គឺគម្ពីរនេះហើយធ្វើជាបន្ទាល់ឲ្យខ្ញុំ
ប៉ុន្តែ អ្នករាល់គ្នាមិនចង់មករកខ្ញុំដើម្បីឲ្យបានជីវិតឡើយ»។(យ៉ូហាន ៥:៣៩-៤០)

ឃ.ទទួលព្រះបន្ទូលរបស់ព្រះគ្រិស្ត

D. ACCEPT THE WORDS OF CHRIST

ម៉ាកុស ៤:២០

២០ រីឯអ្នកដែលបានទទួលគ្រាប់ពូជនៅលើដីមានជីជាតិល្អ
កាលបានស្ដាប់ព្រះបន្ទូលហើយក៏ ទទួល
យកបង្កបង្កើតផល អ្នកខ្លះបានមួយជាសាមសិប
អ្នកខ្លះបានមួយជាហុកសិប អ្នកខ្លះទៀតបានមួយជាមួយរយ។

យើងទទួលព្រះបន្ទូលរបស់ព្រះគ្រិស្តបានល្អឬមិនល្អអាស្រ័យលើ
១.ថាតើយើងស្ដាប់(hear)ព្រះបន្ទូលរបស់ព្រះគ្រិស្តបានឮច្បាស់កម្រិតណា?
២.ថាតើយើងយល់(understand)ព្រះបន្ទូលរបស់ព្រះគ្រិស្តបានល្អត្រឹមត្រូវកម្រិតណា?
៣.ថាតើយើងជឿលើ(believe in)ព្រះបន្ទូលរបស់ព្រះគ្រិស្តបានមុតមាំកម្រិតណា?

ង.ចងចាំព្រះបន្ទូលរបស់ព្រះគ្រិស្ត

E. REMEMBER THE WORDS OF CHRIST

លូកា ៨:១៥

១៥ រីឯគ្រាប់ពូជធ្លាក់ទៅលើដីមានជីជាតិល្អ
ប្រៀបបីដូចជាអស់អ្នកដែលស្ដាប់ព្រះបន្ទូល ហើយ ចងចាំទុក យ៉ាងស្មោះអស់ពីចិត្ត
រហូតដល់បានបង្កើតផលផ្លែជាច្រើនដោយចិត្តស៊ូទ្រាំ។

កូឡុស ៣:១៦

១៦ សូមព្រះបន្ទូលរបស់ព្រះគ្រិស្ត សណ្ឋិតនៅក្នុង បងប្អូនឲ្យបានបរិបូណ៌។
ចូរបង្រៀនប្រដៅនិងដាស់តឿនគ្នាទៅវិញទៅមកដោយប្រាជ្ញាគ្រប់យ៉ាង។

ការទន្ទេញ(memorizing)ព្រះបន្ទូលរបស់ព្រះគ្រិស្តជាមធ្យោបាយដ៏ល្អបំផុត
ដែលជួយយើងឲ្យចងចាំព្រះបន្ទូលរបស់ព្រះអង្គទុកក្នុងចិត្តបាន។

ច.ប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះគ្រិស្ត
F. OBSERVE THE WORDS OF CHRIST
ម៉ាថាយ ២៨:១៩-២០
១៩ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសិស្ស
ហើយធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។
២០ ត្រូវបង្រៀនគេឲ្យ ប្រតិបត្តិតាម សេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។
ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃរហូតដល់អវសានកាលនៃពិភពលោក»។

យើងប្រតិបត្តិតាម(observe)ព្រះបន្ទូលរបស់ព្រះគ្រិស្ត
បានត្រឹមត្រូវឬមិនត្រឹមត្រូវអាស្រ័យលើ
១.ថាតើយើងយល់( understand )ព្រះបន្ទូលរបស់ព្រះគ្រិស្តបានច្បាស់លាស់កម្រិតណា ?
២.ថាតើយើងជឿលើ( believe in )ព្រះបន្ទូលរបស់ព្រះគ្រិស្តបានមុតមាំកម្រិតណា ?
៣.ថាតើយើងចងចាំ( remember )ព្រះបន្ទូលរបស់ព្រះគ្រិស្តបានល្អកម្រិតណា ?

ឆ.ប្រកាសព្រះបន្ទូលរបស់ព្រះគ្រិស្ត E. PREACH THE WORDS OF CHRIST
២ធីម៉ូថេ ៤:២
២ ចូរប្រកាស ព្រះបន្ទូលព្រមទាំងនិយាយហើយនិយាយទៀត ទោះមានឱកាសល្អក្តីមិនល្អក្តី
ត្រូវពន្យល់គេឲ្យដឹងខុសត្រូវ ស្តីបន្ទោស ដាស់តឿន និងបង្រៀនគេដោយចិត្តអត់ធ្មត់គ្រប់ចំពូក។

កូឡុស ៣:១៦-១៧
១៦ សូមព្រះបន្ទូលរបស់ព្រះគ្រិស្តសណ្ឋិតនៅក្នុងបងប្អូនឲ្យបានបរិបូណ៌។
ចូរប្រៀនប្រដៅ និង ដាស់តឿន គ្នាទៅវិញទៅមកដោយប្រាជ្ញាគ្រប់យ៉ាង។
ចូរច្រៀងអរព្រះគុណព្រះជាម្ចាស់ក្នុងចិត្ត
ដោយប្រើទំនុកតម្កើង បទសរសើរ និងបទចំរៀងមកពីព្រះវិញ្ញាណ។
១៧ ការអ្វីក៏ដោយដែលបងប្អូនធ្វើ ទោះជាពាក្យសំដី ឬកាយវិការក្តី
ត្រូវធ្វើក្នុងព្រះនាមព្រះអម្ចាស់យេស៊ូទាំងអស់
ទាំងអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតាតាមរយៈព្រះអង្គផង។




យោងតាម កូឡុស ៣:១៦-១៧ យើងអាចប្រកាសព្រះបន្ទូលរបស់ព្រះគ្រិស្តតាមរយៈ
(១)ការបង្រៀនប្រដៅគ្នា (២)ការដាស់តឿនគ្នា (៣)ការច្រៀងចម្រៀង (៤)ការរាំរបាំ
(៥)ការសម្តែងល្ខោនតាមឱកាសហុចឲ្យដោយយកព្រះបន្ទូលរបស់ព្រះគ្រិស្តជាមូលដ្ឋាន។

យើងអាចនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត

WE CAN ABIDE IN THE WORDS OF CHRIST

១.ដោយស្តាប់ព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ Hear the words of Christ every day

២.ដោយអានព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ Read the words of Christ every day

៣.ដោយយល់ព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ

Understand the words of Christ every day

៤.ដោយទទួលព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ Accept the words of Christ every day

៥.ដោយចងចាំព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ Remember the words of Christ every day

៦.ដោយប្រតិបត្តិតាមព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ

Observe the words of Christ every day

៧.ដោយប្រកាសព្រះបន្ទូលព្រះគ្រិស្តរៀងរាល់ថ្ងៃ។

Preach the words of Christ every day.

## ការអធិស្ឋានឆ្លើយតប

ឱព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់អើយ!
ព្រះបន្ទូលរបស់ព្រះអង្គមានគុណប្រយោជន៍អស្ចារ្យខ្លាំងណាស់សម្រាប់យើងខ្ញុំ
ព្រោះព្រះបន្ទូលរបស់ព្រះអង្គជាព្រះបន្ទូលដ៏មានមហិទ្ធិឫទ្ធិរបស់ព្រះជាម្ចាស់។
ព្រះបន្ទូលរបស់ព្រះគ្រិស្តផ្តល់ជីវិតអស់កល្បជានិច្ចដល់យើងខ្ញុំ
ជូតសម្អាតយើងខ្ញុំឲ្យស្អាត នាំឲ្យយើងខ្ញុំទូលសូមអ្វីៗបានសម្រេច
នាំឲ្យយើងខ្ញុំមានអំណរពេញលេញ នាំឲ្យយើងខ្ញុំមានសេចក្តីសុខសាន្ត
និងនាំឲ្យយើងខ្ញុំបង្កើតផលផ្លែជាច្រើន។
សូមអរព្រះគុណព្រះយេស៊ូចំពោះ
ការដែលព្រះអង្គប្រោសមេត្តាជួយខ្ញុំឲ្យនៅជាប់នឹងព្រះបន្ទូលព្រះអង្គ
តាមរយៈការស្តាប់ឮ ការយល់ដឹង ការទទួល ការចងចាំ ការប្រតិបត្តិតាម
និងការប្រកាសព្រះបន្ទូលរបស់ព្រះអង្គប្រកបដោយប្រាជ្ញាញាណ។ អាម៉ែន!

សំណួរបញ្ជាក់ការអនុវត្ត

1. តើអ្នកស្តាប់ព្រះបន្ទូលរបស់ព្រះគ្រិស្តញឹកញាប់កម្រិតណា?
2. តើអ្នកអានព្រះបន្ទូលរបស់ព្រះគ្រិស្តញឹកញាប់កម្រិតណា?
3. តើអ្នកចេះសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះគ្រិស្តឬទេ? សញ្ជឹងគិតរបៀបណា?
4. តើអ្នកយល់ព្រះបន្ទូលរបស់ព្រះគ្រិស្តច្បាស់លាស់កម្រិតណា?
5. តើអ្នកទទួលព្រះបន្ទូលរបស់ព្រះគ្រិស្តច្រើនកម្រិតណា?
   តើអ្នកចងចាំព្រះបន្ទូលរបស់ព្រះគ្រិស្តល្អកម្រិតណា?
6. តើអ្នកប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះគ្រិស្តត្រឹមត្រូវកម្រិតណា?
7. តើអ្នកថ្លែងព្រះបន្ទូលរបស់ព្រះគ្រិស្តញឹកញាប់កម្រិតណា?
8. តើអ្នកមានផែនការបែបណាដើម្បីឲ្យអ្នកនៅជាប់នឹងព្រះបន្ទូលរបស់ព្រះគ្រិស្ត?
9. សូមទន្ទេញនិងសញ្ជឹងគិតបទគម្ពីរ យ៉ូហាន ៨:៣១; កូឡុស ៣:១៦។